គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)
COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA (COMFREL)
ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Tel: (855) 23 884 150 / 12 942 019, Fax: (855) 23 883 750
E-mail: comfrel@online.com.kh or comfrel@forum.org.kh Site: http://www.comfrel.org
ខុមហ្វ្រែល COMFREL

គណៈកម្មាធិការនាយក
BOARD OF DIRECTORS

លោក ធុន សារាយ
Mr. THUN SARAY
ជាតំណាងទី១ និង
ប្រធាន ADHOC

លោកស្រី អ៊ុង ចាន់ធុល
Ms. OUNG Chanthol
ជាតំណាងទី២ និង
នាយិកា CWCC

លោក យឹម ប៉ូ
Mr. YIM Po អគ្គនាយក
និងនាយក CCPCR

លោក សុខ សំអឿន
Mr. SOK Sam Oeun
នាយក CDP

លោកស្រី ទិវ សារះយេត
Ms. TIV Sarayet
សហនាយិកា WMC

លោក យ៉ង់ គិមអេង
Mr. YONG Kim Eng
ប្រធាន KYA

លោក អ៊ុក វណ្ណដេត
Mr. OUK Vandeth
នាយក LAC

លោក ស៊ីល វិនេត្រ
Mr. SIL Vinet នាយក SEDOC

លោក ភួង សិទ្ធិ
Mr. PHUONG Sith

លោក សិន សែត
Mr. SEN Set

លោក មុំ សារិន
Mr. MOM Sarin
នាយក KKKHRA

លោក ទូច ទុម
Mr. Touch Tum
នាយក VIGILANCE

ស.ប្រ.ក/លេខ ១១/០៧ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មាន
## លទ្ធផលនៃការអង្កេតនៅលើប្រព័ន្ធផ្សព្វផ្សាយ
## ពីថ្ងៃទី ១៦_៣០ ខែ មីនា ឆ្នាំ ២០០៧

*ភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៧*

ខុមហ្វ្រែល បាន និងកំពុងធ្វើការអង្កេតប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិចមួយចំនួនរួមមាន ទូរទស្សន៍ជាតិកម្ពុជា ទូរទស្សន៍ស៊ីធីអិន វិទ្យុជាតិកម្ពុជាក៏រិត FM96MHz វិទ្យុជាតិក៏រិត AM918 KHz (ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកទាំង ៤ នេះបាននិងកំពុងត្រូវបានអង្កេតការផ្សាយចាប់ពីម៉ោង ១៧:០០ ដល់ម៉ោង ២៣:៣០ ជារៀងរាល់ថ្ងៃ) វិទ្យុបារាំងអន្តរជាតិ វិទ្យុអាស៊ីសេរី និងវិទ្យុសំលេងសហរដ្ឋអាមេរិក (វិទ្យុអន្តរជាតិទាំងបីនេះបាន និងកំពុងត្រូវបានអង្កេតការផ្សាយតាមកម្មវិធីរៀងរាល់យប់)។ ខុមហ្វ្រែល ក៏សង្កេតលើប្រព័ន្ធផ្សព្វផ្សាយបោះពុម្ពផងដែរ មានសារព័ត៌មានរស្មីកម្ពុជា និងកោះសន្តិភាព។

## <u>**លទ្ធផលអង្កេតប្រព័ន្ធផ្សព្វផ្សាយរដ្ឋ**</u>

ក្នុងរយៈពេលយុទ្ធនាការណ៍ឃោសនានេះមានតែវិទ្យុជាតិកម្ពុជាក៏រិត **918 KHz តែមួយគត់ដែលបានធ្វើការផ្សព្វផ្សាយ និងលើកឡើងពីគណបក្សនយោបាយចំនួន៤ ហើយក្នុងរយៈពេលដ៏ខ្លីទៀតផង** ខុសកាលពីរយៈពេលមុនយុទ្ធនាការ ដែលប្រព័ន្ធផ្សព្វផ្សាយរដ្ឋមានភាពលំអៀងទៅរកគណបក្សប្រជាជនកម្ពុជា។ គណបក្សនរោត្តមរណឫទ្ធិត្រូវបានផ្សព្វផ្សាយ និងលើកឡើងច្រើនជាងគេរហូតដល់ ១ នាទី ២៤ វិនាទី ទាក់ទងនឹងការទទួចរកការអន្តរាគមន៍ របស់សម្តេចក្រុមព្រះពីបរទេសទាក់ទងនឹងការកាត់ទោសរបស់ព្រះអង្គ។ គណបក្ស សម រង្ស៊ីទទួលបានការផ្សព្វផ្សាយច្រើនលំដាប់ទីពីរ ដូចជាការផ្សាយពីប្រតិកម្មរបស់ឯកឧត្តម ស ខេង ចំពោះការសកម្មជនរបស់គណបក្ស សម រង្ស៊ី នៅស្រុកម៉ោងឫស្សី ថាបានបង្ករជំលោះជាមួយអ្នកភូមិ ហើយបានផ្តល់ព័ត៌មានមិនពិតដល់វិទ្យុអន្តរជាតិ។ គណបក្ស ប្រជាជនកម្ពុជាត្រូវបានលើកឡើង ៨វិនាទី និងគណបក្ស ហ៊្វុនស៊ិនប៉ិចត្រូវបានឮឈ្មោះតែ២វិនាទីប៉ុណ្ណោះ ទាក់ទងទៅនឹងការរាយការណ៍ពីការបើកសម័យប្រជុំរដ្ឋសភា។

## កម្មវិធីផ្សព្វផ្សាយគោលនយោបាយរួមនៃគណបក្សនយោបាយ[១]

កម្មវិធីនេះត្រូវបានផលិតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) និងចាក់ផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិចរបស់រដ្ឋទាំង៣។ ក្នុងកម្មវិធីនេះ គណបក្សនយោបាយទាំង ១២ ត្រូវបានផ្សព្វផ្សាយក្នុងរយៈពេលប្រហាក់ប្រហែលគ្នាគឺចន្លោះពីប្រមាណ ៦%(ស្មើនឹង ២ម៉ោង ២៤នាទី ៤០វិនាទី)ទៅប្រមាណ១០(ស្មើនឹង ៣ ម៉ោង ៤៤ នាទី ១៥ វិនាទី)។ កម្មវិធីនេះនៅក្នុងវិទ្យុ FM96MHz ត្រូវបានអាក់ខានការផ្សាយរយៈពេល ៤ ថ្ងៃ (ពីថ្ងៃទី ២០ ដល់ ២៣ ខែមីនា) ដោយសារតែប៉ុស្តិ៍នេះបានដាច់។ មានគណបក្សនយោបាយចំនួន៥ (គណបក្សប្រជា-ជនកម្ពុជា គណបក្សចំរើននិយមខ្មែរ គណបក្សរណសិរ្សសង្គមជាតិនិយម គណបក្សនរោត្តម រណឫទ្ធិ គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ) ធ្លាប់បាននិយាយលើសពីពេលវេលាដែល គជប ផ្តល់ឱ្យ។

## កម្មវិធីព័ត៌មានសមធម៌នៅក្នុង ទទក (ផ្សាយក្រោយម៉ោងព័ត៌មាន)

គណបក្សនយោបាយទាំង ១២ ត្រូវបានបង្ហាញ ឬឮឈ្មោះនៅក្នុងកម្មវិធីព័ត៌មានសមធម៌ក្នុងរយៈពេលអង្កេតនេះ។

គណបក្សប្រជាជនកម្ពុជាត្រូវបានផ្សព្វផ្សាយប្រមាណ ៣៥% (ស្មើនឹង ៤០នាទី ៥០វិនាទី)។ គណបក្ស សម រង្ស៊ី ត្រូវបានលើកឡើងប្រហែល ២២% (ស្មើនឹង ២៥ នាទី ០៤វិនាទី)។ គណបក្ស ហ៊្វុនស៊ិនប៉ិចទទួលបានប្រមាណ ២១% (ស្មើនឹង ២៤ នាទី ២៩ វិនាទី)។ គណបក្ស នរោត្តម រណឫទ្ធិបានប្រមាណ ១១% (ស្មើនឹង ១២នាទី នាទី ៤៥វិនាទី)។ ចំណែកគណបក្សនយោបាយផ្សេងៗទៀតរួមគ្នាត្រូវបានឮឈ្មោះ ឬ/និង បង្ហាញប្រហែល ១១% (ស្មើនឹង ១២នាទី ៣៦វិនាទី)។ ការអង្កេតនេះបានរកឃើញថា គណបក្សប្រជាជនកម្ពុជា ត្រូវបានផ្សព្វផ្សាយតិចជាងរយៈពេលដែលគណបក្សនេះត្រូវទទួលបានគឺ ៣៨% ខណៈដែលគណបក្សនយោបាយ ផ្សេងៗត្រូវបានផ្សព្វផ្សាយលើសតិចតួចនៃរយៈពេលដែលខ្លួនត្រូវទទួលបាន។

មានតែគណបក្សប្រជាជនកម្ពុជាមួយគត់ដែលត្រូវបានផ្សព្វផ្សាយ បង្ហាញ និងលើកឡើងនៅគ្រប់ការផ្សាយនៃកម្មវិធីនេះទាំងអស់ដែលមានរយៈពេល១២ថ្ងៃ ចំណែកគណបក្ស សម រង្ស៊ីត្រូវបានលើកឡើង និងបង្ហាញក្នុងការផ្សាយរយៈពេល១១ថ្ងៃ។ គណបក្ស ហ៊្វុនស៊ិនប៉ិច និងគណបក្ស នរោត្តម រណឫទ្ធិ ត្រូវបានបង្ហាញ ក្នុងរយៈពេល៩ថ្ងៃស្មើគ្នា។ ចំណែកគណបក្សនយោបាយផ្សេងៗទៀតត្រូវបានផ្សព្វផ្សាយពី ១ ទៅ ៦ថ្ងៃ។

---

១ *កម្មវិធីផ្សព្វផ្សាយគោលនយោបាយរួមនៃគណបក្សនយោបាយ* មិនត្រូវបានវិភាគខ្លឹមសារទេ (ចាត់ទុកក្នុងន័យអព្យាក្រឹត)។

គណបក្សប្រជាជនកម្ពុជាទទួលបានការផ្សព្វផ្សាយបែបវិជ្ជមានទាំងរូបភាព និងខ្លឹមសារ រួមជាមួយនឹងពាក្យសរសើរពីពិធីករ។ ការផ្សព្វផ្សាយ បែបវិជ្ជមានខ្លះៗសំរាប់គណបក្សប្រជាជនកម្ពុជាមានដូចជាការលើកឡើងរបស់ពិធីករថា **ក្បួនដង្ហែរ និងការឃោសនា របស់គណបក្សប្រជាជនកម្ពុជាមានសណ្តាប់ធ្នាប់ល្អ ត្រឹមត្រូវ ការលើកឡើងពីថ្ងៃ៧មករា ការផ្សាយពីសាមាជិក របស់គណបក្ស សម រង្ស៊ី ទៅចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា** ជាដើម និងការបង្ហាញរូបភាព ការរាំច្រៀង សប្បាយ និងការទះដៃអបអរសាទរដោយសមាជិកគណបក្សនេះជាដើម ខណៈដែលគណបក្សផ្សេងៗមិនត្រូវបាន បង្ហាញ ឬឮបែបនេះឡើយ។

ក្នុងកម្មវិធីព័ត៌មានសមធម៌មនេះបានលើកឡើងពីភាពអវិជ្ជមានរបស់គណបក្សនយោបាយចំនួនតែ៣ប៉ុណ្ណោះ។ គណបក្សហ៊្វុនស៊ិនប៉ិចត្រូវបានផ្សព្វផ្សាយបែបអវិជ្ជមាននេះច្រើនជាងគេគឺប្រមាណ៦% (ស្មើនឹង ១នាទី ៣៤វិនាទី នៃការផ្សាយសរុបពីគណបក្សនេះ) ទាក់ទងទៅនឹងការរំខានរបស់គណបក្សនេះចំពោះក្បួនឃោសនារបស់គណបក្សនរោត្តម រណប្ញទ្ធិ។ ចំណែកគណបក្ស នរោត្តម រណប្ញទ្ធិ ទទួលបានការផ្សព្វផ្សាយបែបអវិជ្ជមាននេះប្រមាណ ២% (ស្មើនឹង ១៧វិនាទី) ទាក់ទងនឹងការផ្សព្វផ្សាយពីអវត្តមានរបស់ប្រធានគណបក្សនេះដែលត្រូវបានកាត់ទោសអោយជាប់ពន្ធនាគារពីបទរំលោភសេចក្តីទុកចិត្តលក់ទីស្នាក់ការគណបក្សហ៊្វុនស៊ិនប៉ិច។ ភាពអវិជ្ជមានរបស់គណបក្ស សម រង្ស៊ី ត្រូវបានផ្សព្វផ្សាយ និងឮប្រមាណ១% (ស្មើនឹង ១៦វិនាទី) **ទាក់ទងនឹងការធ្វើសេចក្តីរាយការណ៍ថា សមាជិកគណបក្សនេះចំនួន៣៥រូបបានចាកចេញពីគណបក្ស ហើយទៅចុះចូលជាមួយគណបក្ស ប្រជាជនកម្ពុជា។**

មានតែអ្នកគាំទ្រគណបក្សប្រជាជនកម្ពុជាតែមួយគត់ដែលត្រូវបានសម្ភាសដោយកម្មវិធីនេះ ដោយលើកឡើងពីសមិទ្ធផលរបស់គណបក្សប្រជាជនកម្ពុជាដូចជាគណបក្សប្រជាជនកម្ពុជាបានកសាងទំនប់ទឹក បានជួយប្រជាពលរដ្ឋជួយបូមទឹក កសាងសាលារៀន មន្ទីពេទ្យក្នុងឃុំជាដើម។

កម្មវិធីនេះមិនបានកំណត់អោយច្បាស់ទេថា តើសមិទ្ធផលនានានៅក្នុងឃុំ ដូចជាការកសាងផ្លូវ សាលារៀន មន្ទីរពេទ្យ ។ល។ ជាសមិទ្ធផលរបស់គណបក្សប្រជាជនកម្ពុជា រឺក៏ជាសមិទ្ធិផលរបស់រដ្ឋ។

ក្នុងកម្មវិធីនេះដដែល **ពិធីករមិនបានបែងចែងតួនាទីរដ្ឋ និងក្នុងគណបក្សរបស់បុគ្គលឱ្យបានដាច់នោះទេ** ដូចជាការផ្សាយរៀបរាប់ពីសម្តេច ជា ស៊ីម ជាប្រធានព្រឹទ្ធសភា តែសម្តីផ្ទាល់របស់សម្តេច **ជា ស៊ីម** គឺនិយាយក្នុងនាមប្រធានគណបក្សប្រជាជនកម្ពុជា។ ការបែងចែងមិនច្បាស់នេះ បាននាំមកការពន្យល់ថា ព័ត៌មានគឺនិយាយអំពីអ្នកដឹកនាំស្ថាប័នរដ្ឋ ប៉ុន្តែតាមពិតប្រាកដ វាគឺជាព័ត៌មានរបស់អ្នកដឹកនាំគណបក្សនយោបាយ។

**លទ្ធផលអង្កេតទូរទស្សន៍ ស៊ី ធី អ៊ិន**

ទូរទស្សន៍ ស៊ីធីអ៊ិន បានផ្សាយពីគណបក្សប្រជាជនកម្ពុជាច្រើនលើសលប់ រហូតដល់ ៩២% (ស្មើនឹង ១១នាទី ១២វិនាទី)។ កម្មវិធីទេពកោសល្យ និងស្នាដៃរបស់បណ្ដាញទូរទស្សន៍កម្ពុជា (ស៊ីធីអិន) នៅតែបន្តបង្ហាញ និងផ្សព្វផ្សាយពី គណបក្សប្រជាជនកម្ពុជាតែមួយគត់។ កម្មវិធីដែលមានរយៈពេលមួយម៉ោងនេះនៅតែបន្តសម្ភាសន៍តែចៅសង្កាត់ មកពីគណបក្សប្រជាជនកម្ពុជាដែលបាននិយាយពីសមិទ្ធផលរបស់ខ្លួនដែលបានសាងសង់។ ពិធីករនៅក្នុងកម្មវិធីនេះនៅតែ បន្តនិយាយសរសើរដល់គណបក្សប្រជាជនកម្ពុជា ហើយបាននិយាយបង្អាប់ដល់គណបក្សមិនកាន់អំណាច។

គណបក្សហ្វ៊ុនស៊ិនប៉ិចត្រូវបានផ្សព្វផ្សាយ ៧%។ ចំណែកគណបក្ស សម រង្ស៊ី គណបក្សនរោត្តមរណឫទ្ធិ និងគណបក្សប្រជាធិបតេយ្យខ្មែរត្រូវបានព្វឈ្មោះតែ៣វិនាទីប៉ុណ្ណោះ។ គណបក្សទាំងបីនេះត្រូវបានរាយការណ៍បែបអព្យាក្រឹត ១០០% ទាក់ទងនឹងការផ្សាយពីថ្ងៃបញ្ចប់នៃការធ្វើយុទ្ធនាការបោះឆ្នោត។

**លទ្ធផលអង្កេតប្រព័ន្ធផ្សព្វផ្សាយ វិទ្យុអន្តរជាតិទាំងបី** (RFI, RFA, VOA)

បើបូកបញ្ចូលវិទ្យុអន្តរជាតិទាំងបីរួមគ្នាឃើញថា គណបក្សនយោបាយទាំង ១២ ត្រូវបានលើកឡើង និងផ្សព្វ-ផ្សាយ ក្នុងអំឡុងពេលឃោសនានេះ។ គណបក្សនយោបាយចំនួន ៤ (គណបក្ស សម រង្ស៊ី គណបក្សប្រជាជនកម្ពុជា គណបក្សនរោត្តម រណឫទ្ធិ និងគណបក្ស ហ្វ៊ុនស៊ិនប៉ិច) នៅតែគ្របដណ្ដប់ការផ្សាយនេះដដែល។ គណបក្ស សម រង្ស៊ី បាននាំមុខ ដោយត្រូវបានផ្សព្វផ្សាយប្រហែល ២៣% (ស្មើនឹង ២ ម៉ោង ៥២នាទី ១វិនាទី) នៃរយៈពេលសរុបផ្សាយពីគណបក្សនយោបាយ។ គណបក្សប្រជាជនកម្ពុជា ត្រូវបានផ្សព្វផ្សាយច្រើនលំដាប់ទីពីរគឺប្រហែល ១៩% (ស្មើនឹង ២ម៉ោង ១៩នាទី ២៧ វិនាទី)។ គណបក្សនរោត្តម រណឫទ្ធិ ត្រូវបានផ្សព្វផ្សាយប្រមាណ ១៥% (ស្មើនឹង ១ម៉ោង ៥២នាទី ៣៩វិនាទី)។ គណបក្សហ្វ៊ុនស៊ិនប៉ិច ទទួលបានប្រមាន ១១% (ស្មើនឹង ១ម៉ោង ២៣នាទី ២៦វិនាទី) ហើយចំណែកគណបក្សចំនួន ៨ ទៀត រួមគ្នាត្រូវបានផ្សព្វផ្សាយ ៣២% (ស្មើនឹង ៣ ម៉ោង ២៥ នាទី ៥២ វិនាទី)។

ការផ្សព្វផ្សាយភាគច្រើនគឺ ក្នុងន័យអព្យាក្រឹត។ ការផ្សព្វផ្សាយបែបវិជ្ជមាន និងអវិជ្ជមាន មានតិចតួចសំរាប់គណបក្សនយោបាយមួយចំនួនផងដែរ។

វិទ្យុអន្តរជាតិបានផ្ដោតការផ្សាយខ្លាំងរបស់ខ្លួនទៅលើព្រឹត្តិការណ៍នានាទាក់ទងនឹងការឃោសនាបោះឆ្នោត ដូចជា អំពើហឹង្សា ការរារាំង និងការផ្សព្វផ្សាយពីគោលនយោបាយរបស់គណបក្សនយោបាយផងដែរ។

## លទ្ធផលអង្កេតប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិចទាំងអស់

សរុបលទ្ធផលនៃការអង្កេតប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិចទាំងអស់បានបង្ហាញថា ក្នុងរយៈពេលឃោសនានេះ គណបក្សនយោបាយទាំង ១២ ទទួលបានការផ្សព្វផ្សាយច្រើនធៀបទៅនឹងការផ្សាយមុនពេលឃោសនាបោះឆ្នោត។ ក្នុងនោះ គណបក្សនយោបាយចំនួន ៤ ត្រូវបានផ្សព្វផ្សាយច្រើនជាងគេប្រហាក់ប្រហែលគ្នា។ គណបក្ស សម រង្ស៊ី ទទួលបានប្រមាណ ១៣% (ស្មើនឹង ៧ ម៉ោង ៥នាទី ៣០វិនាទី)។ ប្រជាជនកម្ពុជា ទទួលបានប្រហែល ១៣% (ស្មើនឹង ៦ ម៉ោង ៥៥នាទី ៣៨វិនាទី)។ គណបក្ស នរោត្តមរណឫទ្ធិ បានប្រហែល១២% (ស្មើនឹង ៦ម៉ោង ៩នាទី ២៨វិនាទី) និងគណបក្ស ហ៊្វុនស៊ិនប៉ិច ត្រូវបានផ្សព្វផ្សាយ ១១% (ស្មើនឹង ៥ម៉ោង ៥៣វិនាទី ៨វិនាទី)។ ចំណែកគណបក្សនយោបាយ ៨ ផ្សេងទៀត ដែលទទួលបានការផ្សព្វផ្សាយដ៏តិចតួចបំផុត មុនពេលយុទ្ធនាការឃោសនាបោះឆ្នោតចាប់ផ្តើម ក៏ទទួលបានការផ្សព្វផ្សាយច្រើនផងដែរចន្លោះពី ៥% (ស្មើនឹង ២ម៉ោង ៤៨នាទី ៤៦វិនាទី) ទៅប្រមាណ ៧% (ស្មើនឹង ៣ម៉ោង ៥៩នាទី ៨វិនាទី)។

ខ្លឹមសារផ្សព្វផ្សាយភាគច្រើនលើសលប់គឺក្នុងន័យអព្យាក្រឹត។ ការផ្សព្វផ្សាយបែបអវិជ្ជមាន និងអវិជ្ជមាន មាន មានតិចតួចសំរាប់គណបក្សនយោបាយចំនួន។

វេទិកាដែលមានលក្ខណៈរជដែកដេញដោលគ្នារវាងបេក្ខជនមេឃុំ ឬចៅសង្កាត់ ត្រូវបានផ្សាយដោយវិទ្យុអាស៊ីសេរី តែមួយប៉ុណ្ណោះដែលក្នុងនោះបេក្ខជនមកពីគណបក្សប្រជាជនកម្ពុជាបាននិយាយរហូតដល់ ១៨ នាទី ៥៨ វិនាទី។ បេក្ខជនមកពីគណបក្ស ហ៊្វុនស៊ិនប៉ិច និយាយបាន ១២នាទី ៣៨វិនាទី។ បេក្ខជនមកពីគណបក្ស សម រង្ស៊ីបាន ១២នាទី ៣៤វិនាទី។ បេក្ខជនមកពីគណបក្ស នរោត្តម រណឫទ្ធិ និយាយបាន ៩នាទី ៣០វិនាទី និងមកពីគណបក្សហង្សដាវ៉ាចលនាប្រជាធិបតេយ្យនិយាយបាន ២នាទី ១វិនាទី។

កម្មវិធី ស្ប៉ត(រឿងខ្លី) និងព័ត៌មានស្តីពីការបោះឆ្នោតត្រូវបានផ្សព្វផ្សាយរយៈពេល ១៣ម៉ោង ៧នាទី ៣៦ វិនាទី។ នៅក្នុងអំឡុងពេលនៃការឃោសនានេះ គជប និងអង្គការមិនមែនរដ្ឋាភិបាលបានផលិតស្ប៉ត និងបទចំរៀងជាច្រើនថែមទៀតទាក់ទងនឹងការបោះឆ្នោត ដូចជាជំរុញប្រជាពលរដ្ឋទៅបោះឆ្នោតដោយឆន្ទៈ និងប្រាប់ពេលវេលានៃការបោះឆ្នោតជាដើម។ ស្ប៉តរបស់គជបក៏ត្រូវបានផ្សាយតាមរយៈទូរទស្សន៍ឯកជនស៊ីធីអិនដែរ ដែលកាលពីមុនយុទ្ធនាការឃោសនា ប៉ុស្តិ៍នេះមិនដែលផ្សាយស្ប៉តអប់រំអ្នកបោះឆ្នោតឡើយក្នុងរយៈពេលអង្កេត។ វិទ្យុ វីអូអេ ក៏បានអំពាវនាវឱ្យប្រជាពលរដ្ឋទៅបោះឆ្នោតតាមឆន្ទៈផ្ទាល់ខ្លួនផងដែរ។

បញ្ហាស្ត្រីក្នុងវិស័យនយោបាយ ត្រូវបានផ្សព្វផ្សាយរយៈពេល១១នាទី ២៨វិនាទីដូចជាក្នុងឱកាសវេទិកាការរបស់វិទ្យាស្ថានជាតិប្រជាធិបតេយ្យ (NDI)។

ក្នុងពេលវេលាអង្កេតនេះ ស្ត្រីជាបេក្ខជនសំរាប់ឈរឈ្មោះបោះឆ្នោត ឬមេឃុំ ចៅសង្កាត់ជាស្ត្រីត្រូវបានផ្សព្វផ្សាយ ឬលើកឡើងក្នុងរយៈពេល ១៤នាទី ៥៨វិនាទី ដូចជាការចាក់ផ្សាយពី សមត្ថភាពការងារមេឃុំស្រីដែលផលិតដោយមជ្ឈមណ្ឌលព័ត៌មានស្ត្រីជាដើម។

ការលើកឡើងពីជនពិការក្នុងវិស័យនយោបាយមិនត្រូវបានផ្សព្វផ្សាយទេក្នុងរយៈពេលអង្កេតនេះ។

ការអំពាវនាវអោយទៅបោះឆ្នោត ឬការផ្សាយថាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយច្បាស់លាស់ត្រូវបានផ្សាយតែនៅក្នុងវិទ្យុអាស៊ីសេរី និងវីអូអេ ដូចជាការចាក់ផ្សាយការអំពាវនាវរបស់គណបក្ស សម រង្ស៊ី សុំអោយប្រជាពលរដ្ឋបោះឆ្នោតអោយខ្លួនវិញ ដើម្បីផ្លាស់ប្តូរជីវិភាពរស់នៅ។ ការអំពាវនាវបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជាក៏ត្រូវបានផ្សាយដោយអាស៊ីសេរីផងដែរ។

**<u>លទ្ធផលនៃប្រព័ន្ធផ្សព្វផ្សាយបោះពុម្ព (កោះសន្តិភាព និងរស្មីកម្ពុជា)</u>**

មានតែគណបក្សនយោបាយចំនួន ៤ ប៉ុណ្ណោះ គឺគណបក្សប្រជាជនកម្ពុជា គណបក្ស ហ៊្វុនស៊ិនប៉ិច គណបក្សនរោត្តម រណឫទ្ធិ និងគណបក្ស សម រង្ស៊ី ដែលត្រូវបានផ្សាយនៅក្នុងប្រព័ន្ធផ្សព្វផ្សាយបោះពុម្ព (កោះសន្តិភាព និងរស្មីកម្ពុជា) ទាំងពីររួមគ្នាក្នុងសប្តាហ៍ទីមួយនៃយុទ្ធនាការឃោសនាបោះឆ្នោត។ គណបក្សប្រជាជនកម្ពុជា ត្រូវបានផ្សព្វ-ផ្សាយច្រើន ជាងគេគឺ ៤៣% (ស្មើនឹង ១០អត្ថបទ)។ គណបក្ស សម រង្ស៊ីទទួលបានច្រើនលំដាប់ទីពីរគឺ ៣៥% (ស្មើនឹង ៨អត្ថបទ)។ គណបក្ស ហ៊្វុនស៊ិនប៉ិច ត្រូវបានលើកឡើង ១៣% (ស្មើនឹង ៣អត្ថបទ) និងគណបក្ស នរោត្តម រណឫទ្ធិត្រូវបានផ្សព្វផ្សាយ ៩% (ស្មើនឹង ២អត្ថបទ)។

ប្រព័ន្ធផ្សព្វផ្សាយបោះពុម្ពទាំងពីរនេះក្នុងអំឡុងពេលឃោសនាបោះឆ្នោតបានផ្សព្វផ្សាយពីគណបក្សផ្សេងៗទៀតក្រៅពីគណបក្សប្រជាជនកម្ពុជាច្រើនហើយក្នុងន័យភាគច្រើនលើសលប់គឺវិជ្ជមាន និងអព្យាក្រឹត ដែលខុសពីមុនយុទ្ធនាការដែលគណបក្សទាំងនេះត្រូវគ្របដណ្តប់ដោយព័ត៌មានបែបអវិជ្ជមាន។

អត្ថបទភាគច្រើនទាក់ទង និងការធ្វើយុទ្ធនាការណ៍ឃោសនារកសំលេងរបស់គណបក្សនិមួយៗ។

អត្ថបទដែលមានលក្ខណៈអប់រំអ្នកបោះឆ្នោតត្រូវបានផ្សព្វផ្សាយចំនួនតែ ៣ អត្ថបទប៉ុណ្ណោះ ក្នុងសារព័ត៌មានកោះសន្តិភាពដូចជាអត្ថបទទាក់ទងនឹងការប្រកាសរបស់ គជប ក្នុងការបញ្ជូនសន្លឹកឆ្នោតទៅតាមបណ្តាខេត្ត/ក្រុងនានា។

អត្ថបទដែលមានការអំពាវនាវជាចំហរឱ្យបោះឆ្នោតជូនគណបក្សនយោបាយមានចំនួន២។ ក្នុងអត្ថបទទាំងពីរនេះ គឺជាការគាំទ្រ និងការអំពាវនាវបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជា។

**សូមអរគុណ!**

*សំរាប់ព័ត៌មានលំអិតសូមទាក់ទង:*

- លោក **គល់ បញ្ញា** នាយកប្រតិបត្តិ ខុមហ្វ្រែល ០១២ ៩៤២ ០១៧
- លោក **ម៉ារ សុផល** ប្រធានផ្នែកអង្កេត ខុមហ្វ្រែល ០១២ ៨៤៥ ០៩១
- លោក **គុយ ច័ន្ទដារិទ្ធ** ប្រធានផ្នែកព័ត៌មាន ខុមហ្វ្រែល ០១២ ៨៤៦ ២១១